**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

70th Anniversary of Diplomatic Relations between CAMBODIA - JAPAN

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ៥ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២៣*

## សេចក្តីប្រកាសព័ត៌មានរួម

## ស្តីពីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាន ចំនួន ៣ និង កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ចំនួន ១ ដើម្បីលើកកម្ពស់ភាពធន់សេដ្ឋកិច្ច ជំរុញការអភិវឌ្ឍ និង ការអភិវឌ្ឍធនធានមនុស្ស នៅព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២៣, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាភាគីហត្ថលេខី តំណាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយលោក **NAKAZAWA Keiichiro** អនុប្រធានជាន់ខ្ពស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាន **ចំនួន ៣** និង កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង **ចំនួន ១** ដូចខាងក្រោម÷

**(១) គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសៀមរាប (កញ្ចប់ឥណទានទី ៣) ÷**

ក. គម្រោងមានទឹកប្រាក់ឥណទានសម្បទានចំនួន ២ ០៨១ លានយ៉េនជប៉ុន ។

ខ. វិសាលភាព និង គោលបំណងគម្រោងមានដូចខាងក្រោម÷

គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសៀមរាប មានវិសាលភាពធំៗ ដូចជា សំណង់ស្ថានីយ៍បូមទឹកឆៅដែលមានសមត្ថភាពបូមទឹកឆៅ ៦៦ ០០០ ម$^{៣}$/ថ្ងៃ រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតដែលមានសមត្ថភាពផលិតទឹក ៦០ ០០០ ម$^{៣}$/ថ្ងៃ បំពង់មេចែកចាយទឹកស្អាតប្រវែង ២៩ គ.ម និងបំពង់ចែកចាយទឹកស្អាតប្រវែង ២៥៩ គ.ម។ គម្រោង មានគោលដៅធានានូវការផ្គត់ផ្គង់ទឹកស្អាត និងមានសុវត្ថិភាពជូនប្រជាជនក្នុងក្រុងសៀមរាប និងលើកកម្ពស់ឧស្សាហកម្មទេសចរណ៍នៅក្នុងតំបន់។ នេះជាគម្រោងអាទិភាពមួយដែលបានគិតបញ្ចូលក្នុងផែនការពង្រីកសមត្ថភាពផលិតសម្រាប់ឆ្នាំ ២០១៨-២០២៥ ដែលសំដៅសម្រេចឱ្យបាននូវ "គោលនយោបាយទឹកស្អាតរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ" ដែលកំណត់ថា "នៅឆ្នាំ ២០២៥ ប្រជាពលរដ្ឋរស់នៅតាមទីក្រុងទីប្រជុំជននៅទូទាំងប្រទេស ចំនួន ១០០% ត្រូវទទួលបានសេវាកម្មទឹកស្អាតតាមបំពង់សម្រាប់ប្រើប្រាស់ និងពីប្រភេទផ្សេងៗ "។

គ. ទីតាំងគម្រោង: ខេត្តសៀមរាប។ រដ្ឋាករទឹកស្វយតសៀមរាប (រ.ស.ស) ជាភ្នាក់ងារអនុវត្តគម្រោង។

**(២) គម្រោងកែលម្អផ្លូវជាតិលេខ ៥ ភាគខាងត្បូង ពីព្រែកក្តាមទៅថ្លាម្អម (កញ្ចប់ឥណទានទី ៤) ៖**

ក. គម្រោងមានទឹកប្រាក់ឥណទានសម្បទានចំនួន ៧ ២០៥ លានយ៉េនជប៉ុន ។

ខ. វិសាលភាព និង គោលបំណងគម្រោងមានដូចខាងក្រោម៖

គម្រោងមានគោលបំណងដើម្បីបង្កើនសមត្ថភាពដឹកជញ្ជូន និងធ្វើអោយប្រសើរឡើងនូវភស្តុភារកម្ម នៅកំណាត់ផ្លូវជាតិលេខ ៥ ភ្ជាប់ពី ព្រែកក្តាមនៃខេត្តកណ្តាល ដល់ ថ្លាម្អម ក្នុងខេត្តពោធិ៍សាត់ ដែលតភ្ជាប់ពីរាជធានីភ្នំពេញទៅព្រំដែនកម្ពុជា-ថៃ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ គម្រោងនេះ មានវិសាលភាព ពង្រីកផ្លូវពី ២ គន្លង ទៅ ៤ គន្លង មានសួនកណ្តាលទទឹង ៣ ម៉ែត្រ និងបំពាក់ដោយរនាំងដែកនៅកណ្តាល ដែលមានប្រវែងផ្លូវសរុប ១១៨ គ.ម ក្នុងនោះ ផ្លូវវាងក្រុងកំពង់ឆ្នាំង មានប្រវែង ១១.៨ គ.ម និងផ្លូវវាងក្រុងឧដុង្គ មានប្រវែង ៤.៩ គ.ម។

គ. ទីតាំងគម្រោង: ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និង ខេត្តពោធិ៍សាត់។ ក្រសួងសាធារណការ និងដឹកជញ្ជូន ជាភ្នាក់ងារអនុវត្តគម្រោង។

**(៣) គម្រោងកែលម្អការតភ្ជាប់ផ្លូវជនបទ៖**

ក. គម្រោងមានទឹកប្រាក់ឥណទានសម្បទានចំនួន ២៣ ៦៩២ លានយ៉េនជប៉ុន ។

ខ. វិសាលភាព និង គោលបំណងគម្រោង មានដូចខាងក្រោម៖

គម្រោងមានគោលបំណងពង្រីកបណ្តាញផ្លូវជនបទ ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់ប្រជាជន ក្នុងសកម្មភាពសេដ្ឋកិច្ចសង្គម និងសម្របទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការកែលម្អផ្លូវជនបទដែលមានប្រវែង ៥២៩,៧០ គ.ម (ជាប្រភេទកៅស៊ូ DBST និង បេតុង) មានចំនួន ៣៨ ខ្សែ ដោយរួមបញ្ចូលទាំងស្ពាន និងសំណង់ដោះទឹក នៅបណ្តាខេត្តជុំវិញផ្លូវជាតិលេខ ៥ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅតាមខេត្តគោលដៅ។

គ. ទីតាំងគម្រោង: ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និង ខេត្តបន្ទាយមានជ័យ។ ក្រសួងអភិវឌ្ឍន៍ជនបទ ជាភ្នាក់ងារអនុវត្តគម្រោង។

**(៤) គម្រោងអាហារូបករណ៍ដើម្បីអភិវឌ្ឍធនធានមនុស្ស៖**

ក. ទឹកប្រាក់ហិរញ្ញប្បទានឥតសំណង មានចំនួន ៣៦៦ លានយ៉េនជប៉ុន ។

ខ. គោលបំណង និងវិសាលភាព៖គម្រោងនេះមានគោលបំណងជួយគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សដោយផ្តល់ឱកាសដល់មន្ត្រីវ័យក្មេងរបស់រាជរដ្ឋាភិបាលដែលរំពឹងថានឹងចូលរួមបង្កើតនិងអនុវត្តផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងដើរតួជាអ្នកដឹកនាំក្នុងការអភិវឌ្ឍសង្គមកម្ពុជា។ គម្រោងនេះមានគោលបំណងផងដែរក្នុងការពង្រឹងទំនាក់ទំនងទ្វេភាគី រវាងប្រទេសទាំងពីរ ដោយប្រើប្រាស់បណ្តាញទំនាក់ទំនងមនុស្សតាមរយៈសកម្មភាពសិក្សាសកម្មភាពសង្គម និងបទពិសោធន៍ក្នុងប្រទេសជប៉ុន។ កម្មវិធីអាហារូបករណ៍ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស (JDS) បានចាប់ផ្តើមនៅកម្ពុជាចាប់តាំងពីឆ្នាំ ២០០០ ហើយអស់រយៈពេលជាង ២០ ឆ្នាំ មកនេះ មានមន្ត្រីរាជការវ័យក្មេងប្រហែល ៥០០ នាក់ ដែលបានទទួលអាហារូបករណ៍បន្តការសិក្សាថ្នាក់អនុបណ្ឌិត និងថ្នាក់បណ្ឌិត។

គ. ភ្នាក់ងារអនុវត្តគម្រោង៖ ក្រសួងអប់រំ យុវជន និងកីឡា

ក្នុងឱកាសនៃការរំលឹកខួបលើកទី ៧០ ឆ្នាំនៃទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន ក្នុងនាមជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់នៅព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលជប៉ុន តាមរយៈ JICA ប្តេជ្ញាធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការពង្រឹងភាពជាដៃគូយុទ្ធសាស្ត្ររយៈពេលយូរ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងធនធានមនុស្ស នៅព្រះរាជាណាចក្រកម្ពុជា។

*******************